CEN
CAMBODIA EXPRESS NEWS

# ប្រពន្ធខ្ញុំ ភរិយាខ្ញុំ

**ដោយ អ៊ា អេងទ្រី**

១

មនុស្សជិតកន្លះក្រុងភ្នំពេញចេះតែឆ្ងល់ថា ហេតុយ៉ាងណាបានជា លោកសក្តិស.សុមុនី មិនទាន់មានលោកស្រី? ចំងល់នេះហើរឆ្លងពីមជ្ឈដ្ឋាន មួយទៅមជ្ឈដ្ឋានមួយ បង្កើតបានជារឿងធ្វើឱ្យខ្ញុំជាសាមីខ្លួន ល្បីល្បាញស្ទើរ ស្មើ នឹងតារាឯកភាពយន្ត ។ គួរឱ្យគេឆ្ងល់ដែរ នាយទាហានម្នាក់ពាក់ដល់ទៅ សក្តិ៤ មានរូបសម្បត្តិបវរ តាំងពីកំណើតផ្សំដោយការហាត់រៀនលោតហក់ពីសាលាចំបាំងជួយច្នៃបន្ថែមសាច់ដុំ និងឫកពារពីមីះ៧ មកហ្នឹងម៉ាត់ថែមទៀត គួរអ្វីរកប្រពន្ធមួយគ្រាប់នឹងគេមិនបាន ?

មជ្ឈដ្ឋានខ្លះសន្និដ្ឋានថា ខ្ញុំជាមនុស្សចេះគិតវែងឆ្ងាយ ព្រោះស្រុកកំពុងកើតសង្គ្រាម ដូច្នេះខ្ញុំខ្លាចមេម៉ាយកូនក្រមុំគេ ។ មជ្ឈដ្ឋានខ្លះទៀតថា ខ្ញុំ បែបធ្លាប់មានសង្សារ កំណាន់ចិត្តធ្វើឱ្យខ្ញុំក្អួតឈាម ទើបខ្ញុំស្បថប្រាំធានឈប់រវី រវល់រឿងប្រពន្ធកូនរហូតមក ។

ថ្ងៃមួយនោះអាពួកម៉ាកខ្ញុំម្នាក់ នាំដំណឹងពិសេសមួយមកប្រាប់ខ្ញុំ ទាំងព្រលឹមអុរ ។ វារាយការណ៍ថា មាននារីមួយក្រុមបានលើកយករឿងខ្ញុំទៅ ពិភាក្សា យ៉ាងគគ្រឹកគគ្រេងនៅជុំវិញតុគុយទាវសាច់គោនៅក្នុងហាងផ្សារចាស់ ។ គេថាខ្ញុំកើតមកបែបខ្វះខ្មៅខ្យងខ្លះ ជាពិសេសបែបខ្វះអា "ប្រដាប់ សំខាន់" សំរាប់ស៊ីចុកបុកទំពារជាមួយស្រីបានជាខ្ញុំមិនយកប្រពន្ធ ។ ឮដំណឹង នេះខ្ញុំញញឹមខ្ជិប ។ អាពួកម៉ាកខ្ញុំដែលស្គាល់ក្រយៅខ្ញុំយ៉ាងច្បាស់ ក៏ញញឹមហួសចិត្តដែរ ។ វាឱ្យយោបល់ :

- គ្នាចង់ឱ្យឯងបញ្ចេញក្បាច់ធ្វើឱ្យនាងល្អទាំងនោះ ស្គាល់ ជំងឺគ្រុន ញាក់ម្តងកុំឱ្យក្អេងក្អាងពេក ។

ខ្ញុំសួរថា :

-តើឯងដឹងថា ពួកកញ្ញាផ្សាយដំណឹងទាំងនេះ វាកូនចៅអ្នកណា ? នៅឯណា ?

-គ្នាដឹង ... ព្រោះតែដឹងដូច្នេះហើយទើបចង់ឱ្យឯងបញ្ចេញថ្វីដៃ ។

-សូមមានប្រសាសន៍មក កុំបូរបាច់ច្រើនពេក ។

តាមគ្នាហិតខ្លិនដឹង ពួកនាងជាកូនសិស្សក្រៅរបងសាលាដេកាត៍មួយ ក្រុមដែលចូលចិត្តបង្កើតល្បែង " ជួបគ្នាដោយចៃដន្យ " ជាងការសិក្សា ។

ខ្ញុំខកចិត្តសន្ធឹក នឹងព័ត៌មានចុងក្រោយ ។ តាមពិតទៅខ្ញុំខំគេចមុខ មិនដែលហ៊ានទៅអើតក្បែរសាលាដេកាត៍ នេះជាងមួយខែមកហើយ ព្រោះកញ្ញាកូនកាត់ម្នាក់ប្តេជ្ញាវះទ្រូងរូងយកថ្លើមខ្ញុំទៅឆាខ្ញី កាលណានាងបានជួបនឹងខ្ញុំ ។ រឿងដើមមានមូលហេតុដូចតទៅនេះ

នាងនឹងខ្ញុំបានជួបគ្នាជាដំបូងនៅក្នុងផ្សារណាត់ ក្នុងកំផែងវត្តព្រះកែវ មរកត ។ មិត្តស្រីនាងម្នាក់ដែលធ្លាប់ទំពារអំបុកបញ្ចុកចេកជាមួយខ្ញុំម្តងម្កាល បានណែនាំឱ្យខ្ញុំស្គាល់មិត្តនាងឈ្មោះរ៉ូហ្សែតនេះ ។ តាំងពីថ្ងៃនោះមក យើង ទាក់ទងទៅរកគ្នារបៀបជាមិត្តភក្តិរួចបន្ទាប់មកជាមិត្តរួមកន្ទេលរួមខ្នើយ ... រួមបេះដូង ... ដឹកដៃគ្នាទៅគៀងទាអាឡេវក្បែរ៧ស្ពានសួគ៌ ។ តែថា...ខ្ញុំនេះ វាចំលែកខុសគេខុសឯង ខុសត្រង់ខ្ញុំចូលចិត្តលេងល្បែងក្រឡាប់ផ្កាប់ផ្ងា តែខ្លាច បំផុតត្រង់ពាក្យ " ប្តីប្រពន្ធ " ។ អូនរ៉ូហ្សែតសំលឹងឃើញខ្ញុំជាកំលោះរូប

ស្រស់ មានបុណ្យសក្តិល្មមឱ្យនាងផ្តេកផ្តួលជាគូគ្រងបាន បែបចង់ទាមទារសិទ្ធិជា " លោកស្រី សក្តិ ៤ " ពេញលក្ខណៈច្បាប់ ។ ឃើញស្ថានការណ៍មិនស្រួល ខ្ញុំក៏គេចខ្លួនតាមយុទ្ធសាស្ត្រមិនឱ្យខកខ្លួនទាន់ ។ អាល្បិចថយខ្លួននេះ ខ្ញុំធ្លាប់ប្រើ ប្រាស់វាជាមួយនារីឯទៀតបានស័ក្តិសិទ្ធិរាប់សិបដងមកហើយ តែថាខ្ញុំក៏ត្រូវ ជួបបញ្ហាផ្លាស់ប្តូរ អាសយដ្ឋានពីលិចទៅកើត ពីជើងទៅត្បូង រាប់សិបដងមក ហើយដែរ ។ សព្វថ្ងៃនេះ មុននឹងចេញដើរទៅណាមកណាម្តងៗទាល់តែបើក ក្បួនមើលយាមក្រឡាត្រឹមត្រូវណាស់ទើបហ៊ានយាត្រាចេញ ព្រោះបារម្ភក្រែង សង្គ្រាមស្នេហាផ្ទុះឡើងកណ្តាលផ្សារ នាំផ្អើលគេផ្អើលឯង ។

និយាយឱ្យត្រង់ទៅ ខ្ញុំចេះតែរអើលខ្លួនឯងទេ តែថារឿងធ្លាក់យីអ៊ុន ដល់ថ្នាក់ស្រីៗចោមវាយសំរាតខោកណ្តាលផ្សារនៅមិនទាន់មាននៅឡើយ ។ មិត្តភក្តិជិតស្និទ្ធិរបស់ខ្ញុំ ច្រណែននឹងវាសនាខ្ញុំគ្រប់ៗគ្នា ។ គេថាខ្ញុំបែបមានប្រជ្រុយស្នេហ៍នៅត្រង់កន្លែងកៀនកោះបានជាខ្ញុំ " ស្វាក់ " យ៉ាងនេះ ។ មិត្តខ្លះថា ខ្ញុំចេះស្នេហ៍អូមអាម ឬក៏បានប្រទាលថ្លើមឆ្កែ ប្រទាលសារិកា បានជាសង្សារខ្ញុំ មិនចេះប្រចៃប្រច័ណ្ឌគ្នា ឬក៏ទាមទារថ្លៃទឹកដោះគោម្តងណាសោះ ។ វាផ្ទុយស្រឡះពីពួកគេ ដែលទំរាំតែលៃលកបានមួយមកផ្សំផ្គុំ គ្នាត្រូវតស៊ូលុតក្រាបមុខក្រាសប្រើទឹកលុយ ... ហើយនៅទីបញ្ចប់ច្រើនតែលោកស្រីជាភរិយាក្តិច ខ្ញាំហែកខោ ហែកអាវផ្អើលគេ ផ្អើលឯងចង់មួយកំណាត់ភូមិ ។ មិត្តខ្លះដែល មិនទាន់មានមេផ្ទះ ក៏រកស៊ីមិនសូវកាក់កបដូចខ្ញុំដែរ បើបែរជាកាក់កបវិញ ច្រើនតែហើមគ្រលៀនហួរខ្ទុះផ្លាស់ដំណើរដើរស្ទាបៗរបៀបខ្ចើមដី ។ លោក ប្រុសពីរនាក់ គឺលោក សាមឿន និងលោក សំអួន ជាមិត្តចិត្តមួយថ្លើមបីជា មួយខ្ញុំធ្លាប់ស្ពាយផ្លាំងដីទៅព្យាបាលរោគនៅផ្ទះសំណាក់ទ្វារនាគរបស់ខ្ញុំពីរបី ដងមកហើយ ។

លោកប្រុសដែលនាំយកព័តិមានស្រីៗប្រមាថខ្ញុំមកសារស័ព្ទអំម្បាញ់ មិញ គឺលោកសក្តិពារាជ សំអួន ។ យើងមានឋានន្តរសក្តិខុសគ្នាមែន តែដោយសំអួនជាមិត្តរួមថ្នាក់កាលពីកុមារ និងជាមិត្តរួមជំនាន់ថែមទៀត ទើបយើងហៅរកគ្នាតែពាក្យអាមីងតាំងពីដើមមក ។ ពាក្យពេចន៍របស់ទាហានខ្វះពិធី ការ និងភាពទន់ភ្លន់បន្តិច តែនេះជារបបរបស់យើងក្នុងជីវភាពជាអ្នកច្បាំង ។

ខ្ញុំថ្លែងក្តីអស់សង្ឃឹមប្រាប់មិត្ត :

-អាសំអួន...ឯងចង់ឱ្យ រ៉ូហ្វៃត្រខ្វេះប្រមាត់អញឬ? អញមិនហ៊ានទៅ ផ្សងព្រេងប៉ែកខាងលិចវត្តភ្នំទៀតទេ ។

លោកសំអួន បើកភ្នែកប៉ុនៗពងមាន់ :

-អូហ៍ ! លោកប្រុសកំពូលស្នេហ៍ ចុះថ្នាក់ដល់ខ្លាចស្រីៗហែកខោ ហែកអាវតើ ...អូខេ...បើអ៊ីចឹងគ្នាឈប់នាំដំណឹងអ្វីមកប្រាប់ឯងទៀតហើយ ។

ខ្ញុំងក់ក្បាលផ្ងក់ៗទាំងមិនដឹងខ្លួន ។ អារម្មណ៍ចំលែកមួយកំពុងញាំ ញីដួងចិត្តខ្ញុំយ៉ាងព្រឺព្រួច ។ ខ្ញុំចេះតែស្រម៉ៃថានឹងមានរឿងរ៉ាវចៃដន្យមួយ ចូលមកជ្រៀតជ្រែកក្នុងជីវភាពសុខសាន្តរបស់ខ្ញុំនៅក្នុងពេលដ៏ខ្លីខាងមុខ ។

## ២

រឿងខ្ញុំមិនយកប្រពន្ធ វាមានមូលហេតុចេញមកពីទស្សនៈផ្ទាល់ របស់ខ្ញុំ ។ ចង់អ្នកផងគេថាខ្ញុំឆ្កួត ខ្ញុំវិលខួរ ខ្ញុំបែកឆ្វេងក៏ដោយក៏ខ្ញុំមិនអាចកែ ប្រែការសំរេចចិត្តរបស់ខ្ញុំជាដាច់ខាត ។ ខ្ញុំយល់តែខ្ញុំថាការយកប្រពន្ធ គឺយក ចំណង ប្រាំប្រការមកធ្វើជារបងឃុំឃាំងខ្លួនឯង ឱ្យស្ថិតនៅក្នុង អន្លង់ទុក្ខ ។ តើ មានប្រយោជន៍អ្វីដែលមនុស្សប្រុសម្នាក់ៗមានកំលាំងពលំអាចរកស៊ីធ្វើការ ចិញ្ចឹមខ្លួនរស់ដោយស្រួលនាំគ្នាទៅយកមនុស្សម្នាក់ទៀត ដែលជួនកាលមិន ទាំងធ្លាប់ស្គាល់គ្នាច្បាស់លាស់ផង មកឱ្យរស់នៅជាមួយ សំរាប់បង្កើតឆាកល្ខោនលោមបបោសអង្អែលគ្នារួចទាស់ទែងគ្នារញ៉ាំរញ៉ូវដាក់គ្នា ធ្វើឱ្យខូចអស់សំរស់ ជីវិត ព្រោះដោយសារតែខ្លាចច្បាប់ធម្មជាតិ ឬគ្រាន់តែចង់មានមនុស្សសំរាប់ យំសោករើសឆ្អឹង របស់ខ្លួនដាក់ក្រឡរតែប៉ុណ្ណឹង ? វាមិនមែនជាការចាំបាច់ ដែលគ្រាន់តែគ្មានប្រពន្ធនាំឱ្យប្រុសរស់

នៅមិនកើតនោះទេ ។ មនុស្សយើងកើតឡើងសំរាប់ស្លាប់ទៅវិញ ម្ដេចក៏មិនរក្សាសេរីភាពរបស់ខ្លួនក្នុងការស្វែងរកសេចក្ដីសប្បាយឱ្យអស់ចិត្ត ទំរាំដល់ថ្ងៃចូលម្ឈូស ?

តាមខ្ញុំយល់បុរសដែលមានឈ្មោះថា " ប្ដី " តែងមានបញ្ហារាប់សិប ជំពូកចាក់ស្រេះប្រទាក់គ្នា រហូតដល់ថ្ងៃផុតដង្ហើមបិត ។ លោកប្ដីនៃស្រីក្នុង លោកសុទ្ធតែបានជ្រាបច្បាស់ព្រមទាំងធ្លាប់ភ្លក់រសជាតិជូរចត់នៃជីវិតជាប្ដីនេះ សព្វគ្រប់អស់ហើយ ។

មូលហេតុមួយទៀត ដែលនាំឱ្យខ្ញុំមិនហ៊ានប្រថុយយកប្រពន្ធ ព្រោះ ខ្លាចរឿងសក្ដិមិនទាន់ប្រពន្ធខ្ញុំ ។ ខ្ញុំធ្លាប់ដឹងថា នាយទាហានជាមិត្តភក្ដិខ្ញុំជា ច្រើនខ្លះពាក់សក្ដិ៤ ដូចខ្ញុំដែរ តែលោកស្រីជាភរិយាច្រើនពាក់សក្ដិ៥ ឬពាក់ ផ្កាយមិនដែលតូចជាងប្ដីទេ ។ លោកស្រីទាំងនោះអនុវត្តន៏វិន័យទាហានត្រួត លោកប្ដីយ៉ាងចាស់ដៃ ដើរលេងហួសម៉ោងមិនបាន ឆ្វេចឆ្វាច ឯលិចឯកើតមិន បាន ។ល ។ អំពើអ្វីក៏ដោយឱ្យតែធ្វើខុស " បទបញ្ជាផ្ទៃក្នុង " ច្បាស់ជាបាន ស្ដាប់ធមិទេសនាគ្មានស្គាល់ម៉ោងមិនខាន ។

សរុបសេចក្ដីទៅ សេរីភាពលោកប្រុសទាំងប៉ុន្មាន ត្រូវលោកស្រីក្ដាប់ ជាប់កណ្ដាប់ដៃមិនងាយខ្វេះចេញ ។ លោកស្រីខ្លះរហូតដល ់កេណ្ឌកូន កេណ្ឌ ចៅបង្កើតជាបណ្ដាញចារកិច្ច សំរាប់អង្កេតពិនិត្យសកម្មភាពលោកប្រុសថែម ទៀត ។

នេះហើយជាមូលហេតុ ដែលខ្ញុំមិនយកប្រពន្ធ ។ សព្វថ្ងៃនេះខ្ញុំអាយុ ៣៥ ឆ្នាំផ្លាយ ក្លាយជាកំលោះចាស់ ស្បែកក្រាស់កំលាំងមាន ។ ក្រៅពីធ្វើការ បំរើជាតិក្នុងឋានៈជាមេទ័ពដឹកនាំការប្រយុទ្ធ ជាមួយសត្រូវឈ្លានពាន ខ្ញុំមាន សេរីភាពគ្រប់គ្រាន់ក្នុងការស្វែងរកសេចក្ដីសុខស្រណុកផ្ដើមបានតាមចំណង់ ។ មានអ្វីព្រួយទៀត បើបាយមានលក់ ផ្ទះនៅមានជួលសំរាប់ខ្ញុំដេកស៊ីលាត់សើយ ពេលថ្មើរណាក៏បាន ? បញ្ហាប្រចាំជីវិតខ្ញុំមានតែមួយគត់ គឺបារម្ភក្រែងសង្សារ ចាស់ថ្មីមកជួនពេលគ្នា លំបាកឱ្យខ្ញុំធ្វើចៅក្រមកាត់ សេចក្ដី ។ ក្រៅពីនេះគ្មានលោកស្រីសក្ដិ ៥ ណាមកត្រេងត្រាងចង់អនុវត្តបទបញ្ជាផ្ទៃក្នុងត្រួតត្រាខ្ញុំបាន ជាដាច់ខាត ។ ត្រួតត្រាយ៉ាងម៉េចបើខ្ញុំមិនយកប្រពន្ធ ។

## ៣

ទិវាមួយនោះ ... ក្រោយពីបើកបៀវត្សប្រចាំខែហើយ ខ្ញុំបើកអាតូ យ៉ូតាស្ព័រពណ៌ក្រហមរបស់ខ្ញុំទៅទទួលអូន កល្យាណីសង្សារថ្មោងថ្មីរបស់ខ្ញុំនៅក្បែរផ្សារចាស់ ។ អូន កល្យាណីជាលេខាធិការិនីសហគ្រិនដឹកនាំមួយនៅ ក្នុងរដ្ឋធានី ។ យើងនាំគ្នាជិះរថយន្តប្រកៀកប្រកើយលូកលាន់គ្នា ដូចប្ដីប្រពន្ធ គេពិត១ដែរ ។ ក្រោយពីនាំនាងចូលស្រស់ស្រូបបាយហាងជប់លៀងក្រពះរួច រាល់ហើយ ខ្ញុំក៏ដឹកដៃស្រីស្រស់បញ្ចូលឡានបើកតំរង់មកផ្ទះ ដើម្បីចាប់ផ្ដើម អនុវត្តកម្មវិធីចុងបញ្ចប់ ។

មកដល់ទ្រនុំភ្លាម អូនកល្យាណីកំពូលស្នេហ៍ ដោយធ្លាប់ស្គាល់ផ្លូវ ឡើងទៅស្ថានសួគ៌ច្បាស់ ដូចជាផ្ទះនាងទៅហើយ ក៏គ្រវីចង្កេះនាំនាងដើរចូល ទៅមុនបាត់ ។ ចតឡានស្រួលបួលស្រេចបាច់ ខ្ញុំក៏ភ្លែតឡើងទៅលើផ្ទះដែរ ។ ចូលទៅដល់ភ្ញៀវដែលខ្ញុំក្រឡេកឃើញមុនគេ គឺលោកប្រុស សាមឿន ដែលខំ ញញឹមមករកខ្ញុំ លាយពេបចង់យំបន្តិចផង។ នៅលើឪវង់ មានស្រីចាស់ម្នាក់ ក្មេងម្នាក់កំពុងសំលឹងមើលខ្ញុំ ដោយយកចិត្តទុកដាក់ ហាក់ដូចជាចង់ផ្តិតយក រូបខ្ញុំទៅដាក់តាំងតុ ។ ចំណែកអូនកល្យាណី របស់ខ្ញុំស្រាប់តែបាត់ស្រមោលមិនឃើញមុខនៅក្នុងចំណោមភ្ញៀវសោះ ។ ខ្ញុំឈរភាំងសង្កេតមើលភ្ញៀវពីម្នាក់ទៅម្នាក់ ! ស្រីចំណាស់ធាត់ត្រលុក១ស្លៀកសំឡុយ ពណ៌ខៀវចាស់ ពាក់ អាវដៃខ្លីផ្កាសអុជ១ ។ ម្រាមដៃ និងក លំអដោយបន្តោង និងចិញ្ចៀនពេជ្រ ចាំងរន្ទាល ។ ខ្សែមាសមួយខ្សែ ប៉ុនម្រាមដៃយាស្ដាកពីចង្កេះមានព្យួរកូន សោរ ៤.៥ ដូច កូនត្រដោក ។ ទោះបីមានវ័យចំណាស់បន្តិចក៏ដោយ តែសាច់ឈាមគាត់នៅថ្លាខ្ចី ស័ក្តិសមជាមនុស្សមានសម្បត្តិមហាចក្រ មិនធ្លាប់ស្គាល់ ការនឿយលំបាក ។ វ៉ែនតាស ដែលគាត់ពាក់សំលឹងមើលខ្ញុំ រឹតតែជួយបន្ថែមឱ្យទំរង់មុខគាត់មានអំណាចទ្វេឡើង ។ ក្រឡេកទៅភ្ញៀវម្នាក់ទៀតដែលមាន វ័យក្មេងនៅឡើយ ស្រាប់តែស្លុតចិត្តរិះភ្លេចដកដង្ហើម ។ ក្នុងមួយជីវិតខ្ញុំនេះ ខ្ញុំ មិនទាន់ប្រទះឃើញនារី ណាស្អាតបវរដូចនាងនេះ ។ មនុស្សដើរលេងខូចខិល ដូចខ្ញុំងាយអ្វីរំភើបញាប់ញ័រ ចំពោះ

សំរស់នារី ។ បវរកញ្ញា ដែលល្បីថាស្អាត ណាស់យ៉ាងណា ក៏ខ្ញុំធ្លាប់ឃើញ ធ្លាប់ ហិតធ្លាប់ហូប...រួចធ្លាប់ហីទៅវិញតែ គគោក ។ ចំលែកអ្វីតែភ្ញៀវចំលែករបស់ខ្ញុំម្នាក់នេះ ដែលហាក់មានអនុភាព គ្របដណ្តប់លើដួងចិត្តខ្ញុំឱ្យស្លុតរំភើបបាត់អស់សេចក្តីក្លាហាន ។ ស្រស់ស្រីប្រដាប់ដោយសំលៀកបំពាក់ពណ៌លឿងស្រស់ ស៊ីនឹងសាច់សស្អាតដូចបណ្តូលចេក ។ ទំរង់ភក្ត្រនាង រាងពងក្រពើលំអដោយកេសាខ្មៅរលើបធ្លាក់សំយាកដល់ចង្កេះ ។ នេត្រាទាំងគូខ្មៅយង់ប្រក់ព្រំ ដោយចិញ្ចើមងរស្ទើត ដូចដងកៅទ័ណ្ឌ ។ ច្រមុះស្រួចតូច ធ្មេញត្រឹមស្មើដោយបបូរមាត់ពណ៌ក្រហមពីធម្មជាតិ ។ ថ្ពាល់ទាំងគូប៉ោងរលោងលំអដោយប្រជ្រុយស្នេហ៍ មួយនៅគៀនបបូរមាត់ ខាង ឆ្វេង។ ដងខ្លួនមូលហាប់ទ្រគាកមានគន្លាក់ សុដនក្បំ ផុំឡើងបានជាទេព អប្សរមួយអង្គ ទើបច្យុតមកផែនដី ។ បន្តោងក និងចិញ្ចៀនពេជ្រដេញពន្លឺ ព្រាក១ ក្នុងកញ្ចក់ទូក្បែរនាង អង្គុយ ។

បែបឃើញខ្ញុំឈរភាំងយូរពេកមិនដឹង បានជាលោកប្រុស សាមឿន ក្រោកឈរឡើង លំអោនកាយបន្តិចទៅរកស្រីចំណាស់ផ្តើមហើបមាត់ :

-លោកស្រី...នាង...លោកប្រុសនេះហើយគឺលោកសក្តិ ៤ ស សុមុនី ដែលលោកស្រីត្រូវការជួប... ។

ស្រីចំណាស់ងក់ក្បាលតិច១ តែគ្មានសំដែងកាយវិការគួរសមអ្វីបន្តិច ចំពោះខ្ញុំជាម្ចាស់ផ្ទះ ។ នាងស្រីម្នាក់ទៀតក៏អង្គុយក្នុងឥរិយាបថដដែល ។ ឃើញភ្ញៀវមិនប្រើច្បាប់សុជីវធម៌ ខ្ញុំឯណោះក៏គ្មានការចាំបាច់ត្រូវលើកដៃ សំ ពះសួរវិញដែរ ។ ម្យ៉ាងទៀតខួរក្បាលខ្ញុំកំពុងរវល់ស្រាវជ្រាវរកប្រភពវត្តមាន នៃភ្ញៀវចំលែកនេះ ទាំងអារម្មណ៍ច្រួលច្របល់ ។ ខ្ញុំចេះតែបារម្ភថាភ្ញៀវខ្ញុំនេះ គឺជាម្តាយរបស់នារីមួយរូប ដែលខ្ញុំស៊ីចុកបុកទំពារ ហើយដោះដៃចោល ។ ម្តាយនាងមករកខ្ញុំ ដើម្បីចង់ដឹងថា ខ្ញុំហ្នឹង ជាឪខ្លាត្រីឬ បានជាហ៊ានលូកថ្លើមគាត់ ?

លោកប្រុសសាមឿនបន្តសំដី :

-មុនី ! លោកស្រី និងនាងខាងណេះ ទើបនឹងអញ្ជើញមកពីបាត់ ដំបង គាត់មកអង្គុយចាំជួបឯង ជិតកន្លះថ្ងៃមកហើយ ។

មកដល់ពេលនេះទើបខ្ញុំហើបមាត់រួច :

-សូមលោកស្រី និងអ្នកនាងអភ័យទោស ចំពោះការរង់ចាំយូរបែប នេះ ...អូណែ ! សាមឿនឯងមានយកទឹកក្រូចពីក្នុងទូទឹកកកជូនលោកស្រី និង អ្នកនាងពិសាផងទេ ?

មិនចាំឱ្យអ្នកណាឆ្លើយយ៉ាងម៉េចទាន់ ខ្ញុំយកលេសនេះស្ទុះស្ទារចូល ទៅខាងក្នុងដើម្បីចង់ដឹងថា អូនកល្យាណី របស់ខ្ញុំបាត់ខ្លួនទៅខាងណាហើយ ។ ខ្ញុំបើកទ្វារដើរចូលទៅក្នុងបន្ទប់ដំណេក ឃើញកំពូលស្នេហ៍ខ្ញុំមុខខ្មៅអែ កំពុងឈរញ្ញាក់ដូចលាប់គ្រុនចាញ់ ។ ឃើញខ្ញុំចូលទៅដល់នាងកំរើកបបូរមាត់ ពីរបីដង ទំរាំចេញសំលេង :

-ម្តាយបងមែនទេ ធ្វើម៉េចទៅ ខ្ញុំភ័យណាស់ចង់ស្លាប់ទៅហើយ ?

ខ្ញុំអស់ពីភ័យមែនទែន ទៅជាចង់សើច រួចឆ្លៀតកំប្លែង :

-ពិតហើយ ! គាត់ជាម្តាយក្មេកបង !

-ម្តាយក្មេក ?

-ហ្នឹងហើយ អូនមិនឃើញនាងម្នាក់ស្រស់ដូចទេពអប្សរនោះទេឬ ? នាងជាប្រពន្ធបងហ្នាំ... ។

-ប្រពន្ធបង ?

ខ្ញុំញញឹមសារភាពត្រង់ :

-ល្ងើយ អូនកល្យាណី អូនឈប់ភ័យព្រួយទៅ ... ស្រី១ពីរនាក់នោះ មិនមែនជាម្តាយក្មេក ឬប្រពន្ធបងទេ ។ បងនិយាយកុហកអូន ព្រោះបង ឃើញយាយប៉ិះនោះ ធ្វើឫកដូចម្តាយក្មេកបងសុទ្ធសាធ ។ មិត្តរបស់បងប្រាប់ ថា គាត់មានការមករកបង តែឫកពាគាត់

ដូចម្ដាយកំពុងក្ដៅក្រហាយ នឹងកូនធ្វើខុស ។ ឥឡូវអូនឯងត្រូវតែត្រឡប់ទៅផ្ទះវិញសិន ។ ដើម្បីកុំឱ្យគេសង្ស័យ អូនត្រូវកាន់ថាសចំរៀង ពីរបីនេះទៅផង ។ ឯរឿងបន្ទាប់បន្សំទៀត ចាំបង និយាយដោះសារ ។

រៀបចំឆាកស្រេចបាច់ហើយ ខ្ញុំរុញខ្នងសង្សារខាន លិទ្ធចេញពីបន្ទប់ ដោយមានខ្ញុំដើរជាប់តាមក្រោយ ។ កល្យាណីស្រីវរល្បណ៍ លើកដៃជំរាបលា ភ្ញៀវ រួចដើរតំរង់មាត់ទ្វារយ៉ាងលឿន ។

ខ្ញុំបើកឆាកបញ្ឆេញទេពកោសល្យខាងវោហារភ្លាម

-សូមលោកស្រីអត់ទោស ខ្ញុំរវល់តែរើសថាសចំរៀងឱ្យប្អូនជីដូនមួយ ទើបយូរបន្តិច... អេ ! លោកសាមឿនមកជួយកាប់ ទឹកកកឱ្យគ្នាផង ។ លោកសាមឿនក្រោកឈរ ។ ស្រីចំណាស់រាដៃ :

-បានហើយ ! កុំរវល់អី លោកក្មួយអង្គុយចុះមក អុំមានការ និយាយ ... ។

ខ្ញុំសំរួលខ្លួនអង្គុយលើកៅអីមួយទល់មុខគាត់ទាំងអារម្មណ៍ខ្វល់ខ្វាយ ។

## ៤

ក្រោយពីគ្រហែមផ្ញើមបំពង់ក :

-ក្មួយឯងមានបានដឹងរឿងអ្វីទេ ?

-បាទ...បាទ...លោកស្រីចង់មានប្រសាសន៍ពីរឿងអ្វីដែរ... បាទ ...

-រឿងដែលកើតឡើងនៅបាត់ដំបងនោះហ្នាំ

-រឿងនៅបាត់ដំបង ? ខ្ញុំមិនដែលទៅបាត់ដំបងទេ

-ក្មួយឯងមានប្រពន្ធហើយនៅ ?

( អុញ ! លោកស្រីនេះឡប់សតិទេដឹង ? )

-បាទ...រឿងប្រពន្ធ កូន...នៅទេបាទ...

-ចុះនាងស្រីអំបាញ់មិញ ?

-បាទ នាងជាប្អូនជីដូនមួយខ្ញុំ...នាងមក..

-ក្មួយឯងមិនដឹងរឿងនៅបាត់ដំបងមែនហ្អី ?

-បាទទេ...ខ្ញុំគ្មានប្រព្រឹត្ត...ខ្ញុំ...ខ្ញុំអត់ដឹងអីមែន បាទ ..

លោកស្រីងក់ក្បាល របៀបតុលាការកំពុងសួរអ្នកជាប់ចោទ ។ សំដី សំដៅ និង បុគ្គលិកលក្ខណៈរបស់គាត់ មានអំណាចសំបើម តែហាក់មានបង្កប់ ទុក្ខព្រួយយ៉ាងធ្ងន់នៅក្នុងចិត្ត ។

គាត់ថ្ងូរ :

-ហ៊ឺះ អាទុរយសនោះវាមានគំរោងការល្អិតល្អន់ណាស់ ។ កិត្តិយស កេរ្តិ៍ឈ្មោះរបស់ខ្ញុំវាត្រូវបំផ្លាញខ្ទេចខ្ទីអស់ ... ព្រះម្ចាស់ថ្លៃ អើយ តើឱ្យខ្ញុំយក មុខទៅទុកឯណា ?

ខ្ញុំកាន់តែមឹងមាំងថែមទៀត ។ ឫកពាស្រីចំណាស់ បានផ្លាស់ប្ដូរពី ហ្នឹងម៉ាត់ដូចថ្ម មកទន់ជ្រាយវិញភ្លាមគួរឱ្យអាសូរ..

-មានរឿងហេតុយ៉ាងណាដែរលោកស្រី ខ្ញុំបាទអាចដឹងផងបានទេ ?

-ក្មួយត្រូវតែដឹង...ព្រោះដោយសារតែមានរូបក្មួយឯងហ្នឹង បានគ្រូ សារខ្ញុំត្រូវអាម៉ាសមុខផើបលែងរួច... ។

ចូលសាច់រឿងហើយតើ ខ្ញុំស្ទាបស្ទង់ :

-ខ្ញុំបាទបានប្រព្រឹត្តមិនគប្បី ចំពោះគ្រួសារលោក ស្រីឬ ?

-រឿងនោះគឺ...តើខ្ញុំត្រូវចាប់ផ្ដើម ពីត្រង់ណាមុន លោកក្មួយមឿន ខ្ញុំវិលខួរអស់ហើយ ។

លោកប្រុសសាមឿនញញឹមស្រស់បន្តិចវិញ :

-ខ្ញុំបាទ សូមរៀបរាប់ជំនួសលោកស្រីទៅចុះ គឺថា ដំបូងឡើង មាន មនុស្សម្នាក់ឈ្មោះ ស សុមុនី ពាក់សក្តិ៤ បានទៅរៀបការជាមួយនាងខាង ណេះ...ហើយ...ហើយ...

-ខ្ញុំរៀបការ ! ពុទ្ធោ : ខ្ញុំរៀបការពីអង្កាល់ ? ខ្ញុំឧទានទាំងភ្ញាក់ផ្អើល និងរំភើប ។

ស្រីចំណាស់ដកដង្ហើមធំ និយាយម្តង :

-រឿងចំលែកនោះ មានក្រឡុកក្រលៀតវែងឆ្ងាយណាស់ ... ចាំខ្ញុំ និយាយប្រាប់លោកក្មួយអស់សេចក្តី , ខ្ញុំមិនអួតអាងទេ គ្រួសារខ្ញុំនេះ ជាអ្នកមានមុខមានមាត់ម្នាក់នៅបាត់ដំបង ។ ចាប់តាំងពីប៉ាវាចែកស្ថានទៅ ខ្ញុំធ្លាក់ខ្លួនមេម៉ាយមានតែកូនស្រីមួយជាពន្លឺជីវិត ។ យើងរស់នៅដោយសុខស្រួល គ្មានខ្វល់ពីរឿងខូចខាត ព្រោះខ្ញុំមានក្រុមហ៊ុនជំនួញនៅរោងចក្រឧស្សាហកម្ម ធំ៧ ដូចជា ម៉ាស៊ីនស្រូវ ហាងទឹកក្រូច រោងចក្រផលិតទឹកកក រោងចក្រអារ ឈើជាដើម ។ ក្រៅពីនេះខ្ញុំមានចំការក្រូច-ធូរេន សាម៉ាវរាប់រយហិកតា ដែលអាចឱ្យខ្ញុំ និង កូនស្រីមានប្រាក់ចាយធូរធារមិនចាញ់គេទេ ចូលក្នុងឆ្នាំថ្មីនេះ មានលោកសក្តិ៣ ម្នាក់ចូលទៅដណ្តឹងកូនខ្ញុំ ។ ក្មួយឯងជួយគិតមើលបុណ្យ សក្តិត្រឹមប៉ុណ្ណឹង ហ៊ានចូលទៅសុំធ្វើកូនប្រសារ ខ្ញុំឱ្យផង ។ គ្រួសារក្ររហាម រូបទៀតក៏ខ្មៅដូច ក្អែក...តើខ្ញុំឯណាដាច់ចិត្តលើកកូនទៅឱ្យរងទុក្ខវេទនាជាមួយកើត ? គ្រាន់តែរឿងខ្ញុំបដិសេធមិនព្រមឱ្យកូន បណ្តាលឱ្យលោកសក្តិ៣ នោះច្រឡោតខឹងបោះពាក្យបោះសំដីថា បូព្រឹក្សកូនស្រីខ្ញុំរៀបការជាមួយ បុរសណាផ្សេងទៀតមិនបានជាដាច់ខាត ។ បើហ៊ានរៀបការ គេបាញ់សំលាប់ចោលទាំងម៉ែទាំងកូនឱ្យផ្អើលបាត់ដំបងម្តង ។ រឿងនេះខ្ញុំបានយកជំរាបដល់ អាជ្ញាធរយោធាហើយ តែសព្វថ្ងៃនៅតែមានទាហានជាដៃជើងលោកសក្តិ៣ ដើរក្រវែលផ្ទះខ្ញុំគ្មានលោះពេល ។ សេចក្តីសុខដុមរមនារបស់គ្រួសារខ្ញុំ ចាប់ផ្តើមរង្គោះរង្គើស្ថិតតែក្នុងក្តីព្រួយបារម្ភភ័យខ្លាចចាប់តាំងពីពេលនោះមកដែរ ។ យើងនាំគ្នាសំងំតែក្នុងផ្ទះ ។ ខ្ញុំព្រួយចិត្តតប់ប្រមល់ទល់ពុទ្ធោ តែពីវាសនាកូនស្រីស្ទើរឡប់សតិអស់ ។

ស្រាប់តែកាលពីខែមុននេះ មានបុរសម្នាក់មុខមាត់ រាងរៅស្អាតបាត គួរសមគួររាប់អាន បានចូលទៅជួបនឹងខ្ញុំដល់លំនៅ ។ គេបានរ៉ាយរាប់ប្រាប់ខ្ញុំ ថា ខ្លួនគេឈ្មោះ ស សុមុនី ពាក់សក្តិ៤ ធ្វើការនៅការិយាល័យទី ២ នៃអគ្គ សេនាធិការកងទ័ព ជាតិនៅភ្នំពេញ ។ អាជ្ញាធរយោធាបានចាត់គេឱ្យមកបាត់ដំបង ដើម្បីស៊ើបអង្កេតរឿងទាហានធ្វើផ្តេសផ្តាស់ចំពោះគ្រួសារខ្ញុំ ។ គេអះអាងថាមានគេមកមើលខុសត្រូវហើយ ហើយសុំកុំឱ្យខ្ញុំព្រួយបារម្ភអ្វីតទៅទៀត ។ សំដីសំដៅ និងកាយវិការអោនលំទោនរបស់គេ បានទាក់ទាញចិត្តខ្ញុំឱ្យរំភើប សង្ឃឹមស្លុងស្លយទៅមួយខណៈ ។ និយាយតាមត្រង់ទៅ គឺចាប់ពីពេល បុរសនោះមកធានាអះអាង ការពារសេចក្តីសុខគ្រួសារខ្ញុំ ពេលណាខ្ញុំសង្កេត ឃើញ មិនសូវមានទាហានដើរក្រឡឹងផ្ទះ ខ្ញុំកាន់តែជឿទុកចិត្តខ្ទេរឡើង រហូត ដល់អញ្ជើញគេមកបាយទឹកជាមួយ ។ មិនយូរប៉ុន្មាន យើងក៏ក្លាយទៅជា មនុស្សជិតស្និទ្ធរាប់អានគ្នាយ៉ាងឆាប់រហ័ស ។ គេបានប្រាប់ខ្ញុំថាគេជាកូនប្រុស តែមួយរបស់លោក ទូច វ៉ាន់ថេត ជាមន្ត្រីចូលនិវត្តន៍ ហើយដែលសព្វថ្ងៃល្បី ល្បាយជាអ្នកមានសម្បត្តិធូរធារ ដោយសារមុខរបរជំនួញនៅខេត្តកំពង់ចាម ។ ជួនគ្នាល្អណាស់ ព្រោះពីដើមលោកវ៉ាន់ថេត ធ្លាប់ធ្វើចាល័ដ្ឋ ស្រុក សង្កែ និង ធ្លាប់ជាមិត្តស្និទ្ធស្នាលជាមួយគ្រួសារខ្ញុំដូចបងប្អូន។ អាស្រ័យកត្តានេះហើយ ទើបខ្ញុំពេញចិត្តរហូតហៅគេឱ្យមកសំណាក់នៅលើផ្ទះតែម្តង ។ គេបានទាំង បង្ហាញរូបថតឪពុកម្តាយគេ ដែលគេដាក់ជាប់ក្នុងហោប៉ៅ ឱ្យខ្ញុំមើលផង ។ ខ្ញុំ ជាមនុស្សប្រយ័ត្នប្រយែងណាស់ដែរ ឃើញអ្វីប្លែកខ្ញុំសួរភ្លាម ខ្ញុំធ្លាប់សួរគេថាក្មួយឯងធ្វើទាហានម្តេចក៏មិនដែលឃើញស្លៀកពាក់ទាហាន ? គេឆ្លើយថា គេ មកបំពេញបេសកកម្មសំងាត់ បើស្លៀកពាក់ឯកសណ្ឋានធ្វើម្តេចដើរយកការណ៍ បាន ?

គេបានទាំងហាមខ្ញុំមិនឱ្យនិយាយរឿងសំងាត់របស់គេប្រាប់អ្នកដទៃផង ព្រោះខ្លាចខូចគំរោងការរបស់គេ ក្នុងការជួយការពារសុខទុក្ខគ្រួសារខ្ញុំ ។

ក្នុងពេលទទួលទានបាយជួបជុំគ្នាល្ងាចមួយនោះ គេបាននិយាយយ៉ាង ស្រងូតស្រងាត់ថា គេបានដេកគិតច្រើនយប់ហើយពីរឿងសុខទុក្ខគ្រួសារខ្ញុំទៅថ្ងៃក្រោយ ។ ឧបមាថា ខ្លួនគេបានជូនព័ត៌មានទៅលើឱ្យដកលោកសក្តិ៣ ចេញពីបាត់ដំបង កូនស្រីខ្ញុំក៏ត្រូវរៀបការទៅឱ្យលោកណាម្នាក់ដែរ តែថាការព្រួយបារម្ភ នៅតែស្ថិតជាប់ក្នុងសន្តានចិត្តគ្រួសារខ្ញុំ រហូតទាល់តែដល់ថ្ងៃស្លាប់ទៅវិញ ព្រោះថ្ងៃណាមួយ លែងអីនឹងជួបលោកសក្តិ៣នោះទៀត ? ខ្ញុំភ្លេចចំណុចនេះសូន្យឈឹង ។ ពេលនោះកូនស្រីខ្ញុំបញ្ចេញយោបល់ថា បើវាមិនយកប្តីរហូត តើអាចចៀសវាងពីការ ព្យាបាទបានទេ ? គេឆ្លើយថា រឿងយកប្តីមិនយកប្តីក៏ នៅតែស្ថិតក្នុងគ្រោះថ្នាក់ដដែលជាដដែល មានតែមធ្យោបាយមួយទេប្រហែល រកសេចក្តីសុខក្នុងជីវិតឃើញ ។ ខ្ញុំបង្ខំគេឱ្យនិយាយពីមធ្យោបាយនោះ ។ គេ ក្រហមមុខអិមអៀនមួយសន្ទុះហាក់ដូច មានការទើសទាល់ខ្លាំងណាស់ ។ ទីបំ ផុតគេសុំទោសខ្ញុំជាមុន ទើបចាប់ផ្តើមនិយាយថា កូនស្រីខ្ញុំទាល់តែឱ្យមានប្តី ជាទាហានដែលមានសក្តិធំជាងគូសត្រូវ ទើបអស់ទុក្ខព្រួយប្រចាំជីវិតបាន តែ ថានាយទាហានដែលមានបណ្តាសក្តិពី៤ ឡើងទៅច្រើនតែមនុស្សចាស់បើមាន ក្មេង១ខ្លះក៏គេមានប្រពន្ធកូនអស់ទៅហើយ ។ គេសុំកុំឱ្យខ្ញុំសង្ស័យថា គេ និយាយនេះ ដោយមានបំណងផ្ទាល់ខ្លួនអ្វីផ្សេង ពីរឿងចង់ឱ្យគ្រួសារខ្ញុំបានសុខ ព្រោះកាលណា ស្រុកសាន្តត្រាណ គេសុំចេញពីតំណែងកងទ័ពទៅប្រកបមុខ របរជំនួញវិញហើយ ។ លោកប៉ាគេតំរូវឱ្យគេកាន់កាប់កិច្ចការផ្សេង១ជំនួសគាត់ក្នុងវ័យជរា ។ គេមានបំណងពង្រីកមុខរបររកស៊ី ដោយបើកហាងសាខានៅប្រទេសក្រៅថែមទៀត ហើយដល់ពេលនោះ ប្រហែលគេទៅកាន់កាប់កិច្ចការ ផ្ទាល់ខ្លួនគេនៅហុងកុង ឬនៅសឹង្ហបូរីតែម្តង ។

យោបល់របស់គេសមរម្យគួរពិចារណា ។ ក្នុងរាត្រីនោះ ខ្ញុំដេកគិត មួយយប់ទើសភ្លឺ ។ ច្រកចេញមានតែមួយ គឺចាំបាច់ត្រូវតែឱ្យកូនស្រីមានប្តីទាហាន ។ ឱ្យទាហានដែលអាចពឹងពាក់ផ្ញើវាសនាកូនស្រីបាន គឺលោក ស សុមុ នី ជាកូនរបស់មិត្តភក្តិរបស់គ្រួសារខ្ញុំស្រាប់ ។ ខ្ញុំសំរេចចិត្តដូច្នេះមកពីយល់ថា គ្រួសារលោកមុនី ក៏មានសម្បត្តិស្តុកស្តម្ភមានមុខមានមាត់ អាចឱ្យកូនស្រីខ្ញុំ មានអនាគតល្អទៅថ្ងៃមុខ ។ ម្យ៉ាងទៀត លោកមុនី ក៏នឹងត្រូវចេញពីទាហាន ទៅកាន់កាប់មុខជំនួញយ៉ាងធំ ស្របនឹងសេចក្តីប្រាថ្នារបស់ខ្ញុំមកពីដើមផង ។ គេក៏មានរូបសម្បត្តិសង្ហាសក្តិសមនឹងកូនស្រីខ្ញុំដែរ ។ តើមានអ្វីប្រសើរជាងនេះ ទៅទៀត ។

បន្ទាប់ពីស្នើយោបល់ចាស់ទុំ គ្រួសារ ញាតិមិត្តស្របមតិគ្នាហើយ កន្លះខែក្រោយមក ខ្ញុំក៏ផ្សំផ្គុំគេទាំងពីរតាមប្រពៃណី តែមិនធំដុំណាស់ណាទេ ។ ខ្ញុំរៀបចំកូនចៅដោយប្រញាប់ប្រញាល់ដូច្នេះ ព្រោះមិនចង់ឱ្យមានកង្វល់វែង ឆ្ងាយតទៅទៀតរំពឹងថា ដល់ជួបជុំមាតាបិតា នឹងគ្រួសារខាងប្រុសសព្វគ្រប់ ហើយចាំរៀបចំម្តងទៀត ឱ្យបានអធឹកអធម ។ មូលហេតុមួយទៀតដែលនាំឱ្យខ្ញុំសំរេចចិត្តដូច្នេះ ព្រោះលោកមុនីនោះគេធ្លាប់អះអាងថា ក្នុងមួយជាតិនេះ គេមិនយកប្រពន្ធដាច់ខាត ។ ការរឹងរូសរបស់គេបណ្តាលឱ្យមានទំនាស់ជារឿយ១រវាងគេនឹងឪពុកម្តាយ ។ លោក វ៉ាន់ ថេត ធ្លាប់បានសន្យាថា បើអ្នក ណាមានមធ្យោបាយចេះដឹកនាំឱ្យកូនប្រុសគេយកប្រពន្ធបានគាត់នឹងជូនរង្វាន់ យ៉ាង ច្រើន ។ ឥឡូវបើកូនគាត់យល់ព្រមយកប្រពន្ធដោយចិត្តឯង ហើយ ប្រពន្ធនោះទៀត ជាកូនអ្នកមានពូជអំបូរព្រមទាំងជាកូនមិត្តភក្តិស្រាប់ តើ មានអ្វីធ្វើឱ្យគាត់សប្បាយចិត្តជាងនេះទៅទៀត ?

ក្រោយពីរៀបការបានមួយថ្ងៃ ខ្ញុំក៏នាំកូនទៅចុះសំបុត្រអាពាហ៍ ពិពាហ៍តាមច្បាប់ទំលាប់ ។ មិននឹកស្មានថា មកដល់ផ្ទះវិញផ្ទុះរឿងសោកសៅ ដែលមួយជីវិតខ្ញុំមិនដែលជួបប្រទះ ហើយត្រូវខូចបង់កេរ្តិ៍ឈ្មោះ និងខ្មាស់គេ ដល់ក្អួតឈាមដូច្នេះសោះ ។

រឿងរ៉ាវតទៅទៀត សូមលោកក្មួយមឿនជួយនិយាយបញ្ចប់ផង ខ្ញុំ វិលមុខណាស់ ........ ។

# ៥

ខ្ញុំអង្គុយស្តាប់ភ្ញៀវចំលែកមកអធិប្បាយ ទាំងរំភើប និង មានចំងល់ លាយឡំគ្នា ។ ក្នុងសាច់រឿងមានឈ្មោះខ្ញុំ ជាអ្នកដើរតួចំលែកអស្ចារ្យ ។ លោកប្រុសសាមឿន មិនអនុញ្ញាតឱ្យខ្ញុំសួរអ្វីទាន់ គេចាប់ផ្តើមរៀបរាប់ :

-ខ្ញុំផ្លាស់ទៅធ្វើការនៅកន្លែងសីករងឱ្យរតនៈមណ្ឌល មិនទាន់ទាំង ពេញមួយខែផង ស្រាប់តែបានដំណឹងដោយចៃដន្យថា លោកសក្តិ៤ មុនី មិត្ត ចិត្តមួយថ្លើមមួយរបស់ខ្ញុំរៀបការប្រពន្ធ ។ ដំណឹងនេះធ្វើឱ្យខ្ញុំភ្ញាក់ផ្អើលយ៉ាង ខ្លាំង ។ លោកសក្តិ ៤ ដែលធ្លាប់ស្បថស្បែមិនយកប្រពន្ធមួយជាតិ ត្រឡប់ជាមកលួចរៀបការស្ងាត់ៗនៅក្បែរច្រមុះខ្ញុំ ហើយសូម្បីខ្ញុំជាមិត្តកំសត់កម្រជាមួយគ្នា ក៏មិនប្រាប់ទៀត ។ ខ្ញុំសុំច្បាប់ឡើងរថយន្តទៅបាត់ដំបងភ្លាម ហើយ ក្របួចមាត់ពីចំងាយបំរុងទៅស្រែកអាក្រោសពីអំពើខិលខូចទេ... ទេ... គឺពី អំពើវាខិលមិនព្រមហៅខ្ញុំ ទៅចូលរួមក្នុងពិធីមង្គលការវា ។ ប៉ុន្តែស៊យលើ ស៊យ ព្រោះខ្ញុំដឹងដំណឹងយឺតពេលមួយថ្ងៃទៅហើយ ។ ខ្ញុំទៅដល់បាត់ដំបង ទំរាំស៊ើបរកផ្ទះលោកស្រីឃើញខាតពេលអស់មួយព្រឹកទៀត ។ គឺក្នុងរយៈពេលមួយព្រឹកនោះហើយ ដែលព្រឹត្តិការណ៍ជាប្រវត្តិជីវិតមួយបានសំរេចឱ្យមនុស្ស ម្នាក់មានប្រពន្ធពេញច្បាប់ដោយមិនដឹងខ្លួន ។

ខ្ញុំទៅដល់ផ្ទះលោកស្រី នៅពេលខ្ញុំបំរើកំពុងរុះរោងការរៀបចំតុ កៅ អី និងបោសសំអាតទីធ្លា ។ ក្នុងផ្ទះស្ងាត់ជ្រៀប ។ តាមសេចក្តីស្នើសុំរបស់ខ្ញុំបំរើ ម្នាក់ជូនខ្ញុំទៅកាន់បន្ទប់កូនកំលោះក្រមុំតែម្តង ។ ដោយខឹងពីចំងាយស្រាប់ ខ្ញុំបើកទ្វារបន្ទប់ ដោយមិនបានគោះសុំសេចក្តីអនុញ្ញាត ។ នៅខាងក្នុងខ្ញុំក្រលេក ឃើញប្រុសម្នាក់កំពុងអង្គុយលុតជង្គង់យកដៃអោបទ្រូង ក្នុងសភាពអង្វរកទោរកនារីម្នាក់អង្គុយនៅមុខសំអាង ។ នារីនោះគឺអ្នកនាងនេះឯង ប៉ុន្តែប្រុសនោះ មិនមែនលោកប្រុសមុនីទាល់តែសោះ ។ ខ្ញុំទៅជាស្រឡាំងកាំង ចំហរមាត់ធ្លុង ។ លោកប្រុសនោះក៏បែបស្រឡាំងកាំងជាងខ្ញុំទៅទៀត ព្រោះបន្ទាប់ពីឃើញខ្ញុំ ភ្លាមវាភ័យស្លាំងមុខដូចជួបឱយមរាជ។ ខ្ញុំប្រើចរន្តគំនិតគិតយ៉ាងរហ័សថា ប្រសិនបើខ្ញុំបានព័តិមានដោយច្រឡំទេ គឺខ្ញុំបានរំលោភយ៉ាងអាម៉ាស់ ទៅលើ សិទ្ធិកូនកំលោះ ក្រមុំ នេះយ៉ាងជាក់ស្តែង ។ លោកប្រុសក្នុងបន្ទប់ឃើញខ្ញុំ វា បែបមឹងមាំងដូចទ្រខ្មែរ ក៏ដំឡើងមុខមាំសំលុតខ្ញុំបានមុន គេថាខ្ញុំទើបមកពី ព្រៃកន្ត្លោត ។ បានជាគ្មានចេះសុជីវធម៌ ហ៊ានបើកបន្ទប់គេ ដោយគ្មានឱ្យដំណឹងមុនដូច្នោះ ? គេចង់ច្រានទ្រូងខ្ញុំឱ្យចេញជាបន្ទាន់ តែខ្ញុំសូមទោសគេដោយប្រាប់ពីមូលហេតុដែលខ្ញុំហ៊ានប្រព្រឹត្តបែបនេះ ព្រោះស្មានថាគេជាមិត្តភក្តិ ។ គេ ដំឡើងសរសៃកពន្យល់ខ្ញុំថា ឈ្មោះ មុនី មានរាប់រយពាន់នាក់ ម្តេចខ្ញុំមិនស៊ើបសួរឱ្យច្បាស់លាស់សិន ។ ខ្ញុំបោរមុខរកនិយាយលែងចេញ ។

ស្រាប់តែពេលនោះ ខ្ញុំក្រឡេកទៅឃើញកងអាវុធហត្ថជាតិបីបួន នាក់ និងលោកស្រីខាងណេះដើរតំរង់មក ។ អ្នកដើរមុខគេគឺលោកសក្តិ៤ ពុទ្ធ សាមុដ ជាមេបញ្ជាការ កងរាជអាវុធហត្ថនៅបាត់ដំបង និងជាមិត្តភក្តិសិទ្ធ ស្នាលរបស់ខ្ញុំនិងលោកប្រុសមុនី ។ លោកសាមុដ ញញឹមចាប់ស្មាខ្ញុំ ព្រមទាំងផ្ទៀងខ្លួនអើតចូលមើលទៅខាងក្នុង ។ គេមិចភ្នែកដាក់កូនចៅគេបន្តិច ទើបដឹកដៃខ្ញុំដើរចេញពីមាត់ទ្វារ។ កាន់តែមឹងមាំងថែមឡើង ។ បន្តិចក្រោយមក ទើបយល់ការណ៍ខ្លះវិញ ព្រោះកូនចៅលោកប្រុសសាមុដ កំពុងហែហមលោកប្រុសក្នុងបន្ទប់ដើរចេញមកដោយប្រុងប្រយ័ត្ន ។ លោកស្រីខាងនេះក៏ដួល សន្លប់បាត់មាត់ឈឹង ។ លោក ប្រុស សាមុដ បញ្ជាឱ្យកងអាវុធហត្ថក្រោម បង្គាប់នាំខ្លួនកូនកំលោះទៅស្នងការមុនចំណែកគេនិងខ្ញុំ យើងនាំគ្នាគ្រាហ៍ លោកស្រីទៅកាន់បន្ទប់ទទួលភ្ញៀវ ។ អ្នកនាងខាងណេះទ្រហោយំស្ទុះមកជួយគ្រាហ៍ម្តាយដែរ ។ ក្រោយពីគក់ច្របាច់ឱ្យលោកស្រីដឹងខ្លួនហើយ ទើបលោក សាមុដបង្ហើបរឿងពិតឱ្យយើងបានដឹងតាមដំណើរ ។ គេបានរៀបរាប់ថា ក្រោយពីបានដំណឹងលោកប្រុស មុនីរៀបការប្រពន្ធ គេមួរម៉ៅជេរលោកប្រុសមុនី អស់មួយព្រឹក ។ គេគិតថា ដល់ថ្ងៃរៀបការគេនឹងកេណ្ឌមិត្តភក្ត ព្រមទាំងកូនចៅគេទៅស៊ីផឹកឱ្យអស់បួនដប់ម្តែតុ ដោយមិនបាច់ចងដៃ ។ ផ្សាយប្រាប់ មិត្តភក្តិពីគំរោងការរបស់គេតៗគ្នា ។ គាប់ជួនមានមិត្តម្នាក់ដែលធ្លាប់ឃើញ មុខកូនកំលោះចេញចូលផ្ទះលោកស្រីច្បាស់ បានប្រាប់លោក សាមុដថា លោក សក្តិ៤ មុនី ដែលជិតរៀបការនោះ មិនមែនលោកសក្តិ៤ ស សុមុនី ជាមិត្ត របស់គេទាំង

អស់គ្នាទេ ។ សូម្បីមិត្តគេបញ្ជាក់ច្បាស់លាស់ដូច្នេះហើយ លោក ប្រុសសាមុជ នៅតែមិនអស់ចិត្ត ព្រោះមិនដែលមានអ្នកណា ឈ្មោះដូចគ្នាស្រប គ្នាពាក់សក្តិប៉ុនគ្នាទាំងគ្រប់ម្លេះ ? គេចាត់ឱ្យកងអារុធហត្ថស៊ើបអង្កេតភ្លាម ។ គេស៊ើបរកការពិតឃើញគឺអាស្រ័យដោយសារទៅបើកមើលគល់បញ្ជីក្នុង សៀវភៅដែលចុះសំបុត្រអាពាហ៍ ពិពាហ៍នៅសាលាសង្កាត់ ។ ទាំងឈ្មោះ ទាំង អាយុ ទាំងឈ្មោះឪពុកម្តាយ ទាំងថ្ងៃ ខែ ឆ្នាំដែលកើត គឺជាសំបុត្រកំណើត របស់មិត្តគេទាំងអស់ ។ មកដល់ការិយាល័យវិញភ្លាម គេរើយកលិខិតផ្លូវការមួយច្បាប់មកអានពិនិត្យសាជាថ្មី ។ លិខិតនោះ គឺខាងនាយកដ្ឋានក្រុមនគរបាលជាតិផ្តល់ព័ត៌មានថា មានជនទុច្ចរិតមួយរូបពូកែឆ្នើមខាងលួចប្លន់ចិន បោកប្រាស់ បានគេចខ្លួនពីក្រសួងមានសមត្ថកិច្ច ចូលទៅលាក់ខ្លួននៅក្នុងខេត្ត បាត់ដំបង ។ ឧក្រិដ្ឋជនច្រើនក្លែងបន្លំដើរតួជានាយទាហាន ឬជាអធិការប៉ូលិស ។ គឺដោយសារកត្តាទាំងនេះហើយ ដែលនាំឱ្យលោកប្រុស សាមុជ មានមធ្យោ បាយធ្វើការស្រាវជ្រាវរហូតដល់ចាប់បានអ្នកប្រុសនោះបញ្ចូលគុក ដោយ សាម៉ីខ្លួនបានសារភាពនូវល្បិចកលក្រខ្វក់របស់ខ្លួនសព្វគ្រប់ផង ។ វាបានឆ្លើយបញ្ជាក់ថា ថ្ងៃមួយនោះវាបានចូលលួចក្នុងផ្ទះលោកមុនី ប្រមូលបានខោអាវ និងកាបូបប្រាក់មួយ ។ តែជាអកុសល ក្នុងកាបូបនោះមានតែអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត និងរូបថតឪពុកម្តាយគេមួយសន្លឹក ចំណែកប្រាក់សូម្បីមួយរៀលក៏គ្មានផង ។ ក្រោយមកវាស្រាវជ្រាវប្រវត្តិលោកប្រុសមុនី បាន ច្បាស់លាស់ក៏រៀបឆាកបោកប្រាស់លោក ស្រីខាងណេះ ដោយសំឡឹងឃើញ ទ្រព្យសម្បត្តិនិងអ្នកនាង ។

## ៦

ស្រីចំណាស់ដកដង្ហើមធំ ទើបងាកមករកខ្ញុំ :

-ឥឡូវរឿងនៅបាត់ដំបងចប់ហើយ... នៅតែរឿងកូនស្រីអ៊ុំ នឹងក្មួយ ឯង.......... ។

-រឿងខ្ញុំ ! រឿងខ្ញុំយ៉ាងម៉េចដែរ .... បាទ ?

-ក្មួយឯងនៅតែមិនយល់ទៀត កាលកូនស្រីអ៊ុំចុះសំបុត្រអាពាហ៍ ពិពាហ៍ គឺវាបានរៀបការជាមួយឈ្មោះ ស សុមុនី ជាកូនលោកវ៉ាន់ថេត ហ្នំ ...

-ចុះអាមេបោកប្រាស់នោះ ?

ឈ្មោះពិតរបស់វា គឺអាសែម មិនមែនឈ្មោះស សុមុនី ទេ

-បើដូច្នេះបានសេចក្តីថា អ្នកនាងនិងខ្ញុំបាទ គឺ ...

លោកសាមឿនឆ្លើយជំនួស :

-គឺអ្នកនាងជាប្រពន្ធវា ប៉ុន្តែជាភរិយាពេញច្បាប់របស់ឯង...

ខ្ញុំស្រុញខ្លួននៅក្នុងកៅអី ។ តើត្រូវសើចឬត្រូវយំ ? បើខ្ញុំឆ្លើយថា ខ្ញុំបានប្តេជ្ញាចិត្តមិនយកប្រពន្ធទេ ហាក់ដូចមើលងាយមើលថោកកូនក្រមុំគាត់ពេក ។ បើយល់ព្រមក៏មិនកើតដែរ ព្រោះនាងបានក្លាយជាប្រពន្ធរបស់បុរស ផ្សេងពេញមួយយប់ទៅហើយ ។ តើក្នុងមួយយប់ត្រូវបង់ខាតប៉ុន្មាន ? បុរស ស្នេហ៍ដូចខ្ញុំ តើត្រូវធ្លាក់ខ្លួនដល់ថ្នាក់យកប្រពន្ធមេម៉ាយឬ ?

ខ្ញុំផ្តើមស្ទាបស្ទង់ :

-ក្នុងរឿងនេះ លោកស្រីមានយោបល់យ៉ាងណាដែរ ?

-អ៊ុំមកនេះ គឺមកសួរយោបល់ពីក្មួយ ម្តេចក្មួយសួរអ៊ុំទៅវិញ

-ខ្ញុំ...ខ្ញុំត្រូវធ្វើយ៉ាងម៉េច ?

-ក្មួយឯងសំរេចទៅ... អ៊ុគ្រាន់តែមានភារៈបញ្ជាក់ប្រាប់ក្មួយថា ក្មួយ ឯង និងកូនស្រីអ៊ុ បានក្លាយជាប្តីប្រពន្ធពេញលក្ខណៈច្បាប់ ដោយមានសំបុត្រអាពាហ៍ពិពាហ៍ជាភស្តុតាង ។ បើចង់លុបសំបុត្រអាពាហ៍ពិពាហ៍វិញ ទាល់តែប្តីប្រពន្ធធ្វើពាក្យបណ្តឹងសុំលះលែងគ្នា ទៅតុលាការ ហើយទាល់តែតុលាការ សំរេចសេចក្តីចេញសាលក្រមត្រឹមត្រូវទើបចប់រឿងសព្វគ្រប់ ។

ខ្ញុំចង់តែស្រែកថា បើកុំតែកូនស្រីលោកស្រីឯងឱ្យគេជិះជាន់មួយយប់ ទៅហើយ ខ្ញុំសុខចិត្តកែប្រែការប្តេជ្ញាចិត្តមិនយកប្រពន្ធ ចេញភ្លាម ព្រោះងាយ រកឯណាបានប្រពន្ធស្អាតដូចទេពអប្សរបែបនេះ។ ខ្ញុំគិតដូច្នេះតែខ្ញុំនិយាយផ្សេង :

-រឿងនេះចំឡែកហើយប្រថុចប្រញ៉ុចចំពោះខ្ញុំបាទ សូមលោកស្រី មេត្តាឱ្យខ្ញុំបាទពិចារណាបីបួនថ្ងៃសិន មុននឹងសំរេចចិត្ត .......។

-បាន... អ៊ុមិនបង្ខំក្មួយទេ តែអ៊ុមានសំណូមពរមួយ សុំក្មួយជួយ ។ រឿងនោះ គឺអ៊ុចង់បិទបាំងភាពអាម៉ាស់ ចំពោះភ្នែកញាតិ មិត្តនៅភ្នំពេញខ្លះ ចង់សុំឱ្យទុកដាក់កូន ស្រីអ៊ុដូចជាប្តីប្រពន្ធពិត១ ។ ឪពុកម្តាយរបស់ក្មួយ និង គ្រួសារអ៊ុធ្លាប់រាប់អានគ្នាដូចបងប្អូនបង្កើត ដូច្នេះបូព្រឹក្សក៏អាចចាត់ទុកដូចជា ប្អូនស្រីរបស់ក្មួយទៅហើយ ។ ក្មួយគោងនាំវាដើរលេងបន្លំភ្នែកអ្នកជិតខាង ជួយលើកស្ទួយកិត្តិយស អ៊ុមួយគ្រាសិន ។ ថ្ងៃក្រោយបើក្មួយសំរេចចិត្តយ៉ាង ណាក៏អ៊ុអាចមានលេសសំរាប់និយាយដោះសារលប់លាងការខ្មាសអៀនបានខ្លះ ។

ខ្ញុំអរដូចបានមាសប៉ុនដូងទុំ ។ បានបណ្តើរទេពអប្សរល្អផុតផែនដីដើរ តាមចិត្ត តើមានអ្វីធ្វើឱ្យខ្ញុំរីកថ្លើមជាងនេះទៅទៀត ? ខ្ញុំឆ្លើយយល់ព្រមយ៉ាង អោនលំទោន ព្រមទាំងលួចចោលកន្ទុយភ្នែកទៅរកប្រពន្ធក្រៅខោរបស់ខ្ញុំផង ។

ស្អែកឡើង...គឺក្នុងរយៈពេលតែមួយថ្ងៃសោះ ខ្ញុំបានក្លាយទៅជាអ្នក ស្និទ្ធស្នាលជាមួយគ្រួសារលោកស្រីដាវី យ៉ាងរហ័ស ។ ខ្ញុំអាចចេញចូលក្នុងភូមិ គ្រឹះលោកស្រីនៅ ទួលគោកបានគ្រប់ពេល ដូចនៅផ្ទះរបស់ខ្លួនដែរ ។ លោកស្រី ដាវី ទុកដាក់ខ្ញុំដូចជាកូនប្រសា ពិត១ ចំណែកបូព្រឹក្ស ក៏ចាប់ផ្តើមនិយាយរកខ្ញុំ ឈានទៅរកភាពស្និទ្ធស្នាលបន្តិចម្តង១ ។ រសៀលនោះម្តាយនាងបើកច្បាប់ឱ្យ ខ្ញុំនាំនាងដើរ លេងបំបាត់ទុក្ខព្រួយ តែនាងបានប្រកែកថា នាងមិនហ៊ានជិះទេ ឡានស្ព័រពណ៌ក្រហម ព្រោះឡានធុននេះសំរាប់តែអ្នកលេង ខ្លួនជិះ ផែស្រី១ដូចរូបខ្ញុំជាដើម ។ ខ្ញុំញញឹមខ្ញីប ។ នាងដាក់ផ្លែផ្កាឱ្យគួរតែខ្ញុំខឹងតែមិនដឹងហេតុអ្វី ស្រាប់តែខ្ញុំពេញចិត្តទៅវិញ ។ គិតទៅ ព្រហ្មលិខិតដូចជាជួយជំរុញឱ្យយើងទាំងពីរបែរខ្នងដាក់គ្នាឈប់កើត ហើយព្រោះរសៀលជ្រេបន្តិច ស្រាប់តែរថយន្តផ្ទាល់របស់គ្រួសារ នាងមួយគ្រឿងត្រូវបានអ្នកបើកបរដឹកយកពីបាត់ដំបងមកដល់ភ្នំពេញដែរ ។ ម្តងណេះគ្មានបញ្ហាឡានពណ៌ក្រហមអ្វីទៀតទេ នាងបូព្រឹក្ស និងខ្ញុំត្រូវតែនាំគ្នាដើរលេងតាមសំណូមពររបស់លោកស្រីជាម្តាយ ។ យើងជិះរថយន្តតែពីរនាក់សាសងគ្នាបណ្តើរ ញ៉ាំផ្លែមៀនបណ្តើរដូច សង្សារស្គាល់ចិត្ត ថ្លើមគ្នាយូរមកហើយ ។ ខ្ញុំឆ្លៀតហៅប្រពន្ធពេញច្បាប់របស់ខ្ញុំថា អូន១ម្តង១ ដែរ តែនាងត្រឡប់ជាហៅខ្ញុំ ថាលោក ប្រុស១ដូចមិត្តភក្តិខ្ញុំធ្លាប់ហៅគ្នាទៅ វិញទៅមកអ៊ីចឹងដែរ ។

ដំបូងឡើយ នាងចេញបញ្ជាផ្ទៃក្នុង គួរឱ្យចង់សើច :

-ខ្ញុំសូមហាមលោកប្រុសឱ្យហើយ នៅក្នុងរយៈពេលដែលលោកប្រុស មានឋានៈជាប្តីខ្ញុំពេញច្បាប់ លោកប្រុស មិនត្រូវក្បត់ចិត្ត ខ្ញុំមានស្រីញីបណ្តើរ គ្នាចូលផ្ទះ ដូចថ្ងៃជួបគ្នាដំបូងនោះជាដាច់ខាត ។

-អ្នកណាថាបងខិលខូចមានស្រីញី ? នាងម្នាក់នោះជាបងប្អូនជីដូន មួយបងទេតើ...

-កុំលាក់និងខ្ញុំលោកប្រុសកំហិលស្មានថាគេមើលមិនដឹងថា នាងល្អនោះជាបងប្អូនជង្គង់ប្អូន ឬ ហ៊ឹះ...ឆ្អែតឆ្អន់ពេក ទៅ... ស្រាប់តែប្រកាសមិនព្រម យកប្រពន្ធមួយជាតិ ...។

ចុម! ឃើញទេ...មិនទាន់បានអីផង ប្រពន្ធក្រៅមុងរបស់ខ្ញុំបែបចេញ ឫកសក្តិ៥ លើសខ្ញុំមួយក្រឹតស្រេច ។ តែពេលនេះ ខ្ញុំត្រឡប់ជាពេញចិត្តឱ្យនាង គ្រួតខ្ញុំដូច " ប្តី " ស្រីឯទៀតដែរ ។ បាននាងស្តីបន្ទោសម្តង១ខ្ញុំដូចជារីករាយ ក្នុងចិត្តខុសប្លែកពីធម្មតា ផ្ទុយពី មតិដើមរបស់ខ្ញុំដែលថា ប្រពន្ធបំបាត់ សេរីភាព ប្តី ប្រពន្ធជាចំណងប្រាំប្រការអស់រលីង ។

ខ្ញុំចុចតំរង់ចំណុចខ្សោយនាងម្តង :

-អ្នកប្រុស ដែលបន្លំទៅរៀបការជាមួយអូននោះមានរូបរាងយ៉ាង ម៉េចដែរ ?

នាងបូព្រឹក្ស ញ័រខ្លួនចំប្រប់ ទឹកមុខប្រែជាស្លាំង បង្កប់ការឈឺចាប់ ដល់កំរិត :

-លោកប្រុសសួររឿងហ្នឹងធ្វើអ្វី...លោកប្រុសចង់ឱ្យខ្ញុំក្អួតឈាមស្លាប់ ឬ ?

-ទេ...! ទេ... សូមទោស ... បងសួរលេងទេ ...

-មានរឿងមួយ ដែលខ្ញុំត្រូវជំរាបលោកប្រុសឱ្យបានជ្រាប គឺថាខ្ញុំរៀបការនឹងមនុស្សនោះមែន ដោយសារការយល់ច្រឡំរបស់ម្តាយខ្ញុំ ។ រឿងនេះបានបណ្តាលឱ្យខ្ញុំខូចកិត្តិយសស្ថិតក្នុងសភាពអាម៉ាស និងឈឺចាប់រហូតមួយជីវិត ។ អ្នកដទៃទាំងពួងចាត់ទុកខ្ញុំជាស្រីអភ័ព្វបាត់បង់ព្រហ្មចារីជាមួយ ជនទុច្ចរិតតែតាមការពិតវិញ មានតែទេវតាទេដែលបានជ្រាបច្បាស់ថា ខ្ញុំនៅក្រមុំដដែល ។

ខ្ញុំរំភើបចិត្ត ហើបខ្លួននឹងដំណឹងចំលែកនេះ ។ ដៃខ្ញុំដែលធ្លាប់តែរស់រវើកជាមួយស្រី១តាំងពីដើមមកក៏លូកទៅចាប់ដៃនាងដោយស្វ័យប្រវត្តិ ។ នាងបូព្រឹក្សបណ្តោយឱ្យខ្ញុំច្របាច់ដៃ នាងទាំងអារម្មណ៍អណ្តែតអណ្តូង :

-អូនថាម៉េច ? ចុះយប់ផ្សំដំណេកនោះ ?

-សំណាងល្អ យប់នោះស្រាប់តែខ្ញុំធ្លាក់ថ្ងៃខែ ។ រឿងនេះលោកប្រុស ជឿមិនជឿស្រេចលើលោកប្រុសចុះ ខ្ញុំអស់ពាក្យនិយាយទៀតហើយ ។ បើទុកជាខ្ញុំបើកកាសែតផ្សាយរៀបរាប់ពីសេចក្តីបរិសុទ្ធរបស់ខ្ញុំ ក៏គ្មានអ្នកណាជឿដែរ ។

ខ្ញុំបញ្ឈប់រថយន្តក្រោមម្លប់ឈើមួយក្បែរគៀនថ្មល់ បន្ទំបានប្រាណ នាងមកក្នុងលង្វែកទ្រូង :

-បងជឿ... ជឿដោយស្មោះ... អូនជានារីបរិសុទ្ធសំរាប់... សំរាប់បង ដែរ ។

កញ្ញាបូព្រឹក្សបំរះតិច១ ព្រមទាំងច្រានខ្ញុំចេញ :

-លោកប្រុសកុំចង់បន្លំ ... ខ្ញុំមិនមែនជាស្រីធូរដូចសង្សារលោកប្រុស រាប់ផ្លូននោះទេ ។

-ក្រែងអូនជាប្រពន្ធបងឬ ?

-លោកប្រុស និងខ្ញុំរៀបការពីអង្កាល់ ?

-ចុះសំបុត្រអាពាហ៍ពិពាហ៍នោះ ...មិនគឺ...

-ខ្ញុំរៀបការ នឹងឈ្មោះលោកប្រុសមែន តែកាលណោះមិនមែនលោក ប្រុសទៅសំពះផ្ទឹមជាមួយខ្ញុំឯណា ?

នឹកឃើញដល់ប្រុសម្នាក់ទៀត ទៅបោកប្រាស់រៀបការព្រមទាំងបាន ចូលបន្ទប់ដំណេកជាមួយនាងផងខ្ញុំចុកចាប់ក្នុងចិត្តសំបើម ។ សំដីសួរនាង ចេញភាសាប្រច័ណ្ឌត្រង់១តែម្តង :

-កាលយប់ផ្សំដំណេក អូនបណ្តោយខ្លួនឱ្យគេស្ទាបអង្អែលសព្វសាច់ ចំណែកបងវិញ បងគ្រាន់តែប៉ះពាល់អូនឯងបន្តិចបន្តួច អូនថាបងចង់បន្លំ... តើ បងមិនបានត្រឹមស្មើ នឹងអាទុរយសនោះឬ ?

កញ្ញាបូព្រឹក្សបើកភ្នែកក្រឡោត :

-អ្នកណាមើលឃើញខ្ញុំបណ្តោយខ្លួនឱ្យគេស្ទាបសព្វសាច់ ? ខ្ញុំជាស្រី ក្រមុំបើទុកជាកាលណោះ ខ្ញុំទុកដាក់គេជាប្តីពេញទី ហើយក៏ដោយ ក៏ខ្ញុំនៅមាន ការអៀនខ្មាស ដូចនារីឯទៀតដែរ ។

ខ្ញុំបាត់មាត់ដូចគេចុក ។ ស្ងប់មួយរយៈទើបនាងបន្តសំដី :

-នៅចំពោះមុខច្បាប់ លោកប្រុស និងខ្ញុំជាប្តីប្រពន្ធ ពេញលក្ខណៈតែ ចំពោះស្ថានភាពប្រាកដនិយមវិញ លោកប្រុស និងខ្ញុំទើបនឹងស្គាល់គ្នាមិនទាន់ បានពេញ ៤៨ម៉ោងផង ។ ម្យ៉ាងទៀតយើងទាំងពីរ ជិតដល់ពេលធ្វើពាក្យលះ លែងគ្នានៅតុលាការទៅហើយ តើចាំបាច់អ្វីយើងបង្កើតអនុស្សាវរីយ៍មិនល្អ ចំពោះគ្នាថែមទៀត ?

-ទេ..ទេ. អ្នកណាថាបងត្រូវធ្វើពាក្យលះលែងគ្នា?

-ចុះលោកប្រុសប្ដេជ្ញា ថាមិនយកប្រពន្ធមួយជាតិ នោះ ?

-បងសុខចិត្តលប់ការសំរេចចិត្តចោល ឱ្យតែអូន យល់ព្រម...

-ចុះទំលាប់ខិលខូចមានស្រីញីរាប់មិនអស់ តើលោកប្រុសអាចលប់ ចោលបានខ្លះដែរ ?

-លប់ចោលទាំងអស់ ...

-លោកប្រុសមិនខ្លាចគេសើចពេបជ្រាយថា យកប្រពន្ធសំណល់ពីគេ ទេឬ ?

-បងអត់ខ្វល់ នឹងអ្នកណាសើចយំអ្វីទាំងអស់ ឱ្យតែអូននៅបរិសុទ្ធ សំរាប់បង ។

-បើដូច្នេះអូនក៏លែងមានកង្វល់ និងការឈឺចាប់តទៅទៀតហើយ ។ លោកម៉ែមានជំនឿយ៉ាងមាំថា រូបបងពិតជាអាចជួយស្ដារកិត្តិយស គ្រួសារខ្ញុំ ឱ្យមានរស្មីដូចដើមវិញបាន ។

អស់មានវាចានឹងថ្លែង ។ យើងទាំងពីរអោបរិតគ្នា ឈប់ខ្វាសអ្នកណា ទាំងអស់ ។